ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ ព្រហស្បតិ៍ ១២ រោច ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤*
*រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០២០*

# សេចក្តីប្រកាសព័ត៌មាន
## កិច្ចប្រជុំកិច្ចប្រជុំកំពូលអាស៊ាន-ចិន លើកទី ២៣
## ស្តីពី "ការត្រួតពិនិត្យឡើងវិញនៃកិច្ចសហប្រតិបត្តិការ និង ទិសដៅអនាគតអាស៊ាន-ចិន"
## ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០២០

នារសៀលថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០២០ នេះដែរ, ក្នុងនាមជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, បន្ទាប់ពីកិច្ចប្រជុំកំពូលអាស៊ានពេញអង្គ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ ចូលរួមកិច្ចប្រជុំកិច្ចកំពូល "**អាស៊ាន-ចិន លើកទី ២៣**" តាមប្រព័ន្ធវីដេអូ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ កិច្ចប្រជុំនេះដឹកនាំដោយឯកឧត្តម **ង្វៀន សួន ហ៊្វុក** (Nguyen Xuan Phuc) នាយករដ្ឋមន្ត្រីនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម ។

ក្រោមប្រធានបទ "**ការត្រួតពិនិត្យឡើងវិញនៃកិច្ចសហប្រតិបត្តិការ និង ទិសដៅអនាគតអាស៊ាន-ចិន**" កិច្ចប្រជុំកំពូល"**អាស៊ាន-ចិន លើកទី ២៣**" នេះ បានផ្តោតកិច្ចពិភាក្សាជាចម្បងលើបញ្ហាប្រឈម ដែលរួមមានបញ្ហាសុខភាពសាធារណៈ និងស្ថានភាពសង្គម-សេដ្ឋកិច្ច ដែលបណ្តាលមកពីវិបត្តិនៃជំងឺកូវីដ-១៩ នៅក្នុងតំបន់ទាំងពីរ ជាដើម ។ អង្គប្រជុំ បានសង្កត់ធ្ងន់ អំពីភាពចាំបាច់នៃការបង្កើនកិច្ចសហការរវាងអាស៊ាន និងចិន ក្នុងការពង្រឹងសាមគ្គីភាព និងកិច្ចសហប្រតិបត្តិការរួមគ្នា ក្នុងការឆ្លើយតបទៅនឹងជំងឺរាតត្បាត និងក្នុងការស្តារស្ថេរភាព និងងើបឡើងវិញនូវស្ថានភាពសង្គម-សេដ្ឋកិច្ច បន្ទាប់ពីវិបត្តិនេះត្រូវបានបញ្ចប់ តាមរយៈយន្តការដែលមានស្រាប់ រួមមាន "**ផែនការអនុវត្ត ២០១៦-២០២០**" និង "**កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ACFTA)**" ក៏ដូចជា ស្វែងរកនូវយន្តការសហប្រតិបត្តិការថ្មីៗបន្ថែមទៀត ។

ថ្នាក់ដឹកនាំនៃប្រទេសអាស៊ាន ស្វាគមន៍ និងវាយតម្លៃខ្ពស់ចំពោះការចូលរួមចំណែករបស់ប្រទេសចិន ក្នុងការពង្រឹង និងលើកកម្ពស់ចំណងមិត្តភាពអាស៊ាន-ចិន ព្រមទាំងក្នុងការជំរុញគំនិតផ្តួចផ្តើម **"ភាពជាដៃគូអាស៊ាន-ចិនស្តីពីសេដ្ឋកិច្ចពណ៌ខៀវ"** និង **"ចក្ខុវិស័យភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-ចិន ឆ្នាំ ២០៣០"** ។

ថ្នាក់ដឹកនាំនៃប្រទេសអាស៊ាន-ចិន បានប្តេជ្ញាបន្តគាំទ្រគោលការណ៍ពហុភាគីនិយម និងបានស្នើឱ្យមានការបង្កើនកិច្ចសហប្រតិបត្តិការនៅក្នុងតំបន់ទៅលើការកសាងជំនឿទុកចិត្ត និងរក្សាភាពធន់នៃសង្គម-សេដ្ឋកិច្ចនាពេលអនាគត, ការបើកចំហរវិរហូរពាណិជ្ជកម្មសេរី, ការតភ្ជាប់ខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងតំបន់, និងការអនុវត្តសេដ្ឋកិច្ចឌីជីថល ។ ថ្នាក់ដឹកនាំនៃប្រទេសអាស៊ាន បានសំដែងការស្វាគមន៍និងគាំទ្រ ចំពោះការប្រកាសរបស់ប្រទេសចិន ដែលបានចាត់ទុកវ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩ ជា **"ទំនិញសាធារណៈ"** និងការបន្តផ្គត់ផ្គង់ថ្នាំ និងបរិក្ខារពេទ្យក្នុងតំបន់អាស៊ានសម្រាប់ការសង្គ្រោះបន្ទាន់ លើកកម្ពស់សុខភាពសាធារណៈ ព្រមទាំងជំនួយដទៃទៀតសម្រាប់ការស្តារ និងងើបឡើងវិញ នៃសង្គម-សេដ្ឋកិច្ចនៅក្នុងតំបន់អាស៊ាន ក្រោយកូវីដ-១៩ ។

ជាមួយគ្នានេះ, ថ្នាក់ដឹកនាំនៃប្រទេសអាស៊ាន ក៏បានសំដែងការពេញចិត្ត និងគាំទ្រចំពោះការប្តេជ្ញាចិត្តរបស់ឯកឧត្តម **លី ខឺឈាង** (Li Kequiang) នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន ក្នុងការបង្កើនកិច្ចសហប្រតិបត្តិការ, ការជួយដល់តំបន់អាស៊ាន និងការដោះស្រាយបញ្ហាផ្សេងៗទៀត តាមយន្តការសន្តិវិធី ដោយឈរលើស្មារតីសាមគ្គីភាព និងវិបុលភាពដល់ប្រជាជនទាំងអស់នៃតំបន់ទាំងពីរ ។